# ឌុច បន្តធ្វើសក្ខីកម្មស្របពេលដែលមានការជំទាស់ពីក្រុមការពារក្ដី

**ដោយ វ៉ែនឌល ឌីហ្វាល់កូ**

**ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១២**

*កែសម្រួលដោយ ជា ផល្លា*

នៅថ្ងៃអង្គារ ទី២០ ខែមីនា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ផ្ដើមកិច្ចដំណើរការសវនាការលើករណី០០២បន្តទៀត ។ កាលវិភាគសម្រាប់ថ្ងៃនេះគឺ ត្រូវបន្តសក្ខីកម្មរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលជាទណ្ឌិតក្នុងករណី០០១ ។ ទន្ទឹមនឹងសាធារណជនចាប់អារម្មណ៍សក្ខីកម្មរបស់ ឌុច និងជាសាក្សីដ៏សំខាន់សម្រាប់ករណី០០២នេះ ហេតុការណ៍មួយទៀតក៏កើតឡើងដែរ គឺសហចៅក្រមអន្តរជាតិបម្រុង ឡូរ៉ង់ កាស្ពើ អានស្មឹត លាលែងពីតំណែង ។ អ្នកចូលរួមតាមដាននៅតុលាការ ជជែកគ្នាពីបញ្ហានេះជាហូរហែទាក់ទងទៅនឹងបញ្ហានៃការលាលែងនេះ ។ ជាហេតុធ្វើឲ្យអ្នកតាមដានមិនសូវនិយាយពីការធ្វើសក្ខីកម្មរបស់ ឌុច ប៉ុន្មានទេ ។

## ព្រះរាជអាជ្ញាបន្តសួរសំណួរទៅ ឌុច

ក្រោយពីចៅក្រម និល ណុន ប្រកាសបើកដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឌុច ត្រូវបាននាំចូលមកកាន់កៅអីសម្រាប់សាក្សី ។ ថ្ងៃម្សិលមិញ ឌុច ស្លៀកសំលៀកបំពាក់ពណ៌ខៀវដែលជាឯកសណ្ឋានរបស់អ្នកទោសកម្ពុជា តែថ្ងៃនេះ ឌុច ពាក់អាវខាងក្រៅពណ៌សដែលជាទម្លាប់របស់គាត់ក្នុងអំឡុងពេលសវនាការ០០១ ។ មុននឹងដំណើរការចាប់ផ្ដើម ឌុច បានស្នើទៅអង្គជំនុំជម្រះសុំ “អង្គុយផ្អែក” ព្រោះគាត់ពិបាកទ្រោបខ្លួនទៅមុខកាលពីម្សិលមិញ ។ ប្រធាន និល ណុន អនុញ្ញាតហើយប្រគល់តួនាទីនេះទៅព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញា សេង ប៊ុនឃៀង បន្តសួរសំណួរទៅកាន់ ឌុច បន្តពីថ្ងៃម្សិលមិញដោយដំបូងបានចោទសួរថា តើមនុស្សប្រភេទណាត្រូវបានចាត់ទុកថាជាសត្រូវ? ឌុច បានឆ្លើយដោយរៀបរាប់ពីករណីអ្នកទោសជនជាតិបារាំងម្នាក់នៅមន្ទីរម-១៣ឈ្មោះ ហ្វ្រង់ស័រ ប៊ីហ្សូ ដែលជាអ្នកស្រាវជ្រាវនៅប្រាសាទអង្គរវត្ត ។ ឌុច បាននិយាយថា ប៉ុល ពត បានលើកលែងទោសឲ្យ ហ្វ្រង់ស័រ ប៊ីហ្សូ តែអ្នកដែលមកជាមួយគាត់ត្រូវបានសម្លាប់ចោលពេលបន្ទាប់មកទៀត ។ ឌុច បានផ្ដល់សក្ខីកម្មទាក់ទងទៅនឹងប្រភេទមនុស្សដែលត្រូវបញ្ជូនទៅមន្ទីរម-១៣ ហើយការិយាល័យរបស់មន្ទីរនេះត្រូវបានផ្លាស់ប្ដូរចំនួនបីដង ។ វ៉ាន់ រ៉េត រស់នៅតំបន់នោះ ហើយជាកម្មាភិបាលនៅតំបន់កាលពីពេលនោះ ។ ឌុច បន្តទៀតទេ ពេលខ្លះគាត់ត្រូវជិះកង់ទៅមន្ទីរនោះទៅវិញទៅមកដែលមានចម្ងាយ២០ គីឡូម៉ែត្រ ។

គាត់បានចូលប្រជុំជារៀងរាល់ខែអំពីបក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានទៅជួបជាមួយ វ៉ន វ៉េត ពាក់កណ្តាលយប់ក្រោយពីមានករណីអ្នកទោសគាស់គុករត់រួចនៅមន្ទីរ ម-១៣ ។ ឌុច បាននិយាយពីពេលដែលគាត់ចូលបក្សដំបូង និងការតែងតាំងជាប្រធានមន្ទីរ ម-១៣ ។ គាត់បានជួបជាមួយ សុន សេន ពេលដែលគាត់រៀននៅវិទ្យាល័យស៊ីសុវត្ថិ ក្រោយមកមិត្តរួបថ្នាក់ម្នាក់បានណែនាំឲ្យគាត់ជួបជាមួយ សុន សេន ។ ឌុច និយាយថា គាត់មិនចង់ជួបជាមួយ សុន សេន ទេនៅពេលនោះ ព្រោះគាត់ចង់រៀនចប់សិនមុននឹងចូលជាមួយចលនាកុម្មុយនីស្ត ។ ឌុច បានឲ្យដឹងថា វ៉ន វ៉េត ក្លាយជាប្រធានរបស់ ឌុច ក្នុងខែឧសភា ឆ្នាំ១៩៧១ និងជាប្រធានរហូតដល់ សុន សេន ចូលមកជំនួស ។ សុន សេន ក្លាយជាប្រធានផ្ទាល់របស់គាត់កាលពីដើមឆ្នាំ១៩៧៣ឬដើម១៩៧៤ ។

ក្រោយមក ព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយតាមអេក្រង់កុំព្យូទ័រ ដែលឯកសារនោះគឺជាសេចក្តីថ្លែងការណ៍របស់ នួន ជា ក្នុងអំឡុងពេលខួបនៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា ហើយព្រះរាជអាជ្ញាបានសួរទៅ ឌុច ថា មានស្គាល់ឯកសារនេះដែរឬទេ? ឌុច និយាយថា គាត់មិនចូលរួមខួបកំណើតកងទ័ពទេ តែគាត់ដឹងថាមានខួបនេះ ។ ក្នុងអំឡុងដើមរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានឮតាមវិទ្យុថា នួន ជា ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្តីទី ។

ក្រោយមក សេង ប៊ុនឃៀង បានបង្ហាញឯកសារទីពីរទៅ ឌុច ដែលឯកសារនោះគឺជាសៀវភៅទង់បដិវត្តន៍ ។ ឌុច និយាយថា ទង់បដិវត្តន៍គឺ ជាសៀវភៅបោះពុម្ពផ្សាយប្រចាំខែរបស់បក្សកុម្មុយកម្ពុជា ហើយសមាជិកបក្សទាំងអស់ត្រូវបានសៀវភៅនោះ ។ ក្រោយមក ឌុច ត្រូវបានតម្រូវឲ្យពន្យល់ពីពាក្យ “ជណ្តើមប្រជាជន” ។ ឌុច បានឆ្លើយថា ពាក្យនេះមានន័យថា “ជណ្តើមប្រជាជនពីខ្មាំង” ដែលប្រើពាក្យនេះដើម្បីជំនួសពាក្យ “ជម្លៀសប្រជាជន” ដែលមានន័យថា យកប្រជាជនចេញពីតំបន់ខ្មាំង ។ ទាក់ទងទៅនឹងសំនួរផ្សេងទៀតនៃការជម្លៀសជនជាតិវៀតណាម ឌុច បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាយកមនុស្ស រួមទាំងជនជាតិវៀតណាមផង ចេញពីខ្មាំងដើម្បីកុំឲ្យប៉ះពាល់ជាមួយខ្មាំង ។ ឌុច បញ្ជាក់ថា មានមនុស្សម្នាក់ដែល ឌុច មិនប្រាប់ឈ្មោះពិត ត្រូវបានជម្លៀសចេញ ពីឧត្តុង្គទៅជនបទ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងតំបន់នោះ ។

លោក ម៉ៃឃើល ផេស្តមែន មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា បានបន្ទរក់ដោយស្នើសុំឈ្មោះពិតនូវអ្វីដែល ឌុច បានលើកឡើង ។ ព្រះរាជអាជ្ញាបានឆ្លើយតបវិញថា មនុស្សម្នាក់នោះគឺជាសាក្សីនៅក្នុងករណី០០១ដែលបានធ្វើសក្ខីកម្មរួចហើយ ។ ក្រោយមក អង្គជំនុំជម្រះបានប្រាប់ទៅមេធាវី ផេស្តមែន ថាបើចង់ដឹងសូមទៅស្រាវជ្រាវរកមើលទៅនិងឃើញហើយ ។

ក្រោយមក ឌុច ត្រូវបានសួរថាតើពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើគាត់នៅទីណា? ឌុច បានឆ្លើយថា កាលនោះគាត់មិននៅភ្នំពេញទេ តែនៅខែមិថុនា

ឆ្នាំ១៩៧៥ សុន សេន បានហៅគាត់ឲ្យទៅភ្នំពេញដើម្បីចូលរួមវគ្គរៀនសូត្រ។ ពេលមកដល់ភ្នំពេញ ឌុច រស់នៅក្នុងផ្ទះមួយក្នុងបរិវេណស្ថានីយ៍អយស្ម័យយាន។ ក្រោយពីចប់វគ្គរៀនសូត្រ ឌុច ត្រូវបានបញ្ជូនទៅការិយាល័យរបស់អតីតមន្ត្រី លន់ នល់។ គាត់ត្រូវបានចាត់តាំងឲ្យឆែកឆេរមើលផ្ទះរបស់អតីតមន្ត្រីរបស់ លន់ នល់ ដើម្បីរកមើលឯកសារមុននឹងគាត់ត្រូវបានតែងតាំងជាអនុប្រធានមន្ទីរស-២១។ ក្រោយពីប្រធានរបស់គាត់ឈ្មោះ ណាត ត្រូវបានដកចេញ ឌុច ចូលជំនួសជាប្រធានមន្ទីរស-២១។ ឌុច បានឲ្យដឹងថា មន្ទីរស-២១គឺ ដើម្បីសួរចម្លើយរកចម្លើយសារភាព។ ហើយការធ្វើទារុណកម្មគឺ «ជាការអនុវត្តន៍ជាធម្មតាតាមពីសម័យឥស្សរៈមកម្ល៉េះ» មន្ទីរស-២១យកគំរូចាស់«តាមទម្រង់ដូចសម័យឥស្សរៈក្នុងការសួរចម្លើយ»។ អ្នកដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១នឹងត្រូវតែកម្ទេចចោល។ កាលពីសម័យ ណាត ជាគ្រាន អ្នកដែលត្រូវបានចាប់ខ្លួន គឺជា«បញ្ញាវ័ន្ត»។ ក្រុមមនុស្សមួយក្រោយមកទៀតគឺអ្នកដែលមកពីរោងចក្រក្រដាសដែលត្រូវបានចាប់ខ្លួនក្រោយពីរោងចក្រនោះត្រូវភ្លើងឆេះ។ ក្រុមទីបីគឺអ្នកនេសាទថៃប្រមាណជា៣០០នាក់។ ក្រុមទីបួនគឺចាមមូស្លីមដែលរកស៊ីចិញ្ចឹមគោ។

នៅពេលសួរអំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបញ្ជូនទៅមន្ទីរស-២១ ឌុច បានឆ្លើយថា នៅចុងឆ្នាំ១៩៧៥ កម្មាភិបាលជាន់ខ្ពស់បីនាក់រួមមាន សៀន និង កុយ ធួន ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅមន្ទីរស-២១។ ក្រោយពីហេតុការណ៍ផ្ទុះគ្រាប់បែកនៅជិតវាំង កម្មាភិបាលច្រើនទៀតត្រូវបានបញ្ជូនមកមន្ទីរស-២១ដែរ។ ចម្លើយសារភាពរបស់ កុយ ធួន នៅឆ្នាំ១៩៧៦ នាំទៅរកការធ្វើបន្សុទ្ធកម្ម«ទ្រង់ទ្រាយធំ» នៅភូមិភាគឧត្តរ។

សេង ប៊ុនឃៀង បានសួរថា តើមនុស្សប៉ុន្មាននាក់ត្រូវបានចាប់ខ្លួននិងសម្លាប់នៅមន្ទីរស-២១ ឌុច បានឆ្លើយថា គាត់មិនដឹងពីចំនួនពិតប្រាកដទេ តែតាមបញ្ជីដែលប្រមូលបានដោយព្រះរាជអជ្ញាមានអ្នកទោសជាង១២០០០នាក់ស្លាប់នៅទីនោះ។ ឌុច បញ្ជាក់ដែរថា គាត់មិនដែលជំទាស់ទៅនឹងចំនួននៅក្នុងបញ្ជីនេះទេ។

បន្ទាប់មក ឌុច លើកឡើងអំពីតួនាទីនិងការទទួលខុសត្រូវរបស់គាត់នៅមន្ទីរស-២១ដោយបញ្ជាក់ថា មន្ទីរស-២១គឺជា «កងឯករាជ្យ»របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ផ្ទាល់ជាអ្នកទទួលខុសត្រូវកិច្ចការពីមួយថ្ងៃទៅមួយថ្ងៃ រួចរាយការណ៍ទៅ សុន សេន រហូតដល់ថ្ងៃទី១៥ ខែមេសា ទើបឈប់ ព្រោះពេលនោះ សុន សេន ត្រូវបានផ្លាស់ចេញ។ ឌុច បន្តទៀតថា គាត់«ជួបជាមួយបងធំទីពីរ នួន ជា» ពេលដែលគាត់ជាអ្នករាយការណ៍ជា«ប្រចាំ»។

ក្រោយមក ឌុច បានបញ្ជាក់ថា គាត់បានអាននិងសង្ខេបចម្លើយសារភាព រួចរាយការណ៍ទៅថ្នាក់លើទាក់ទងទៅនឹងចម្លើយសារភាពទៅកាន់មេរបស់គាត់គឺ នួន ជា។ ហ៊ីរ ដែលជាអនុប្រធានរបស់

ឌុច មានតួនាទីនាំអ្នកទោសទៅសម្លាប់នៅជើងឯក។ ក្រោយមក ហ៊ីរ មានកំហុស ដូច្នេះកិច្ចការទាំងអស់ត្រូវបានត្រួតពិនិត្យដោយ ឌុច «គ្រប់ពេលវេលា»។ ក្រៅពីកិច្ចការដែលគាត់ត្រូវធ្វើ គាត់ក៏មានតួនាទីអប់រំកម្មាភិបាលក្រោមបង្គាប់របស់គាត់ដែរ។ ឌុច និយាយថា គាត់ទទួលបានការអនុញ្ញាតពីតាម៉ុក ដើម្បីរៀបការ តែគាត់មិនមានសិទ្ធរើសប្រពន្ធតាមចិត្តឯងទេ។ ឌុច មានកូនពីរនាក់មុនពេលវៀតណាមចូលមកកម្ពុជានៅចុងឆ្នាំ១៩៧៨។

ក្រោយពេលវៀតណាមចូលមក ឌុច បានធ្វើដំណើរទៅភាគពាយ័ព្យ ហើយគាត់បានសុំបាយមេដឹកនាំខ្មែរក្រហមហូបនៅពេលនោះ។ ឌុច និយាយថា ពេលនោះ គាត់មិនដែលចូលរួមកិច្ចប្រជុំអ្វីទេ ហើយក៏មិនគ្រប់គ្រងមន្ទីរឃុំឃាំងទៀតដែរ។ ពីឆ្នាំ១៩៨៦ដល់១៩៨៨ គាត់ត្រូវបានបញ្ជូនទៅទីក្រុងប៉េកាំង ប្រទេសចិន តាមការបញ្ជារបស់ ប៉ុល ពត ដើម្បីបង្រៀនសិស្សចិន។ ពេលដែលគាត់ត្រលប់មកវិញ គាត់ទទួលបន្ទុកខាងសរសេរសៀវភៅដើម្បីបង្រៀនសិស្សបឋមសិក្សាក្រោមរបបបក្សកុម្មុយនីស្តកម្ពុជា។

សេង ប៊ុនឃៀង បានសួរទៅ ឌុច អំពីទីកន្លែងដែលគាត់រស់នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ឌុច បានឆ្លើយថា គាត់ប្តូរពីសំឡូតនៅពេលដែលផ្ទះរបស់គាត់ត្រូវចោរប្លន់។ គាត់ក្លាយជាគ្រូបង្រៀននៅសំឡូត នៅនៅទីនោះរហូតដល់ខែឧសភា ឆ្នាំ១៩៩៩ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលកម្ពុជា។

## អៀង សារី ហត់នឿយនិងស្នើតាមដានដំណើរការសវនាការពីចម្ងាយដូចធម្មតា

ហៀបនីងអង្គជំនុំជម្រះប្រកាសសម្រាក មេធាវី អាង ឧត្តម របស់ជនជាប់ចោទ អៀង សារី ស្នើសុំឲ្យកូនក្តីរបស់ខ្លួនទៅតាមដានតាមប្រព័ន្ធសោតទស្សន៍វិញ។ ដូចសព្វដង ចៅក្រមតម្រូវឲ្យមានលិខិតជាលាយលក្ខណ៍អក្សរ និងហត្ថលេខារបស់ជនជាប់ចោទផ្ទាល់ចំពោះការស្នើសុំ។

## វិសាលភាពនៃការចោទសួរត្រូវយកមកពិភាក្សា

បន្ទាប់ពីសម្រាក ចៅក្រម និល ណុន បានថ្លែងអំពីវិសាលភាពនៃការសួរសំណួរដោយសារតែអ្វីដែល ឌុច និយាយស្ថិតនៅក្រៅវង្វង់នៃប្រធានបទ។ លោកចៅក្រមបានស្នើទៅគ្រប់ភាគីទាំងអស់ឲ្យសួរសំណួរឲ្យត្រូវនឹងចំណុច។

មេធាវី ដេស្តមែន បានក្រោកឡើងនិងលើកឡើងថា គាត់មិន «ឮ ឌុច និយាយច្រើនសោះ» ទាក់ទងទៅនឹងករណី០០២ វគ្គមួយនេះ។ មេធាវីរូបនេះបានបញ្ជាក់ទៀតថា សាក្សីដែល ឌុច មិន

និយាយចំឈ្មោះនោះត្រូវបានស្គាល់ជាសាធារណក្នុងករណី០០១ ។ មេធាវីបានស្នើថា ឌុច មិនគួរលាក់ឈ្មោះឬប្រាប់ឈ្មោះក្លែងក្លាយទេព្រោះការដែលនិយាយបែបនេះនាំឲ្យមានការភ័ន្តច្រឡំ ។

ទីបញ្ចប់ មេធាវី ដេស្តមែន បានបញ្ជាក់ថា អង្គជំនុំជម្រះបានរៀបរាប់ពីអកប្បកិរិយារបស់គាត់រួចហើយកាលពីថ្ងៃម្សិលមិញ ហើយអកប្បកិរិយានោះត្រូវបានចាត់ទុកថា សមរម្យ ។

មេធាវីបានបញ្ជាក់ថា គាត់គឺជាសមាជិករបស់ក្រុមប្រឹក្សាមេធាវីជាតិកម្ពុជាផង និងក្រុមប្រឹក្សាមេធាវីរបស់ទីក្រុងអាំស្ទែដាំផង ហើយគាត់មានភារកិច្ចនិងផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងទៅកាន់ស្ថាប័នទាំងពីរនេះ ។ មេធាវី ដេស្តមែន បានបន្តថា គាត់សូម«លើកទឹកចិត្តដល់អង្គជំនុំជម្រះឲ្យធ្វើបែបនេះ» ទើប«អ្នកជំនាញ»ណាមួយពិចារណានឹងស្ថានភាពនេះ និងសកម្មភាពរបស់គាត់ ។

វីល្លៀម ស្មីត បានឆ្លើយតបទៅនឹងឯកសារនៃសក្ខីកម្មរបស់ ឌុច ដោយអះអាងថា ការធ្វើសក្ខីកម្មចំនួនបួនម៉ោងរបស់ ឌុច គឺសុទ្ធតែមានការពាក់ព័ន្ធទាំងអស់ព្រោះព្រះរាជអាជ្ញាចង់ដឹងពី ឌុច ថាតើគាត់ដឹងអំពីចម្លើយទៅនឹងរចនាសម្ព័ន្ធនិងមនោគមនវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាឬអត់? លោកបានបញ្ជាក់ថា ព្រះរាជអាជ្ញាចង់ប្រើឈ្មោះក្លែងក្លាយពេលនិយាយឈ្មោះសាក្សី ។ ក្រោយមក លោកចៅក្រម និល ណុន បានណែនាំទៅគ្រប់ភាគីទាំងអស់ឲ្យប្រើប្រាស់ឈ្មោះក្លែងក្លាយសម្រាប់សាក្សីទាំងអស់ និងប្រគល់តួនាទីនេះទៅភាគីព្រះរាជអាជ្ញា សេង ប៊ុនឃៀង ដើម្បីបន្តសំណួរទៅសាក្សី ឌុច ។

## ព្រះរាជអាជ្ញាចាប់ផ្តើមបន្តសំណួរទៅកាន់ ឌុច

សេង ប៊ុនឃៀង បានសួរ ឌុច អំពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានឲ្យដឹងថា នៅក្នុងឯកសារមនោគមន៍របស់បក្សកុម្មុយនីស្តកម្ពុជា«ជំហានដំបូង» គឺត្រូវបែកប្រភេទប្រជាជនជាបីប្រភេទ ៖ ទីមួយគឺដើម្បីបញ្ចុះបញ្ចូលកម្លាំងប្រជាជនឲ្យចូលបដិវត្តន៍ ទីពីរគឺដើម្បីបញ្ចុះបញ្ចូលកម្លាំងដែលមិនទាន់ចុះចូល និងទីបីដើម្បីផ្តាច់ខ្លួននិងកម្ទេចពួកប្រឆាំង ។ ឌុច បានបញ្ជាក់ថា គាត់មិនចាំទេថាទ្រឹស្តីនេះអាចយកមកអនុវត្តបានឬអត់ទេនៅក្នុង«សង្គមពិត»នោះ ។ ឌុច បានបន្តថា បក្សកុម្មុយនីស្តកម្ពុជា តម្រូវឲ្យសមាជិកបក្សទាំងអស់បែងចែកខ្លួនឯងឲ្យច្បាស់ពីសត្រូវដែលមិនរស់នៅក្នុងតំបន់«រំដោះ» ។ សមាជិកបក្សទាំងអស់ត្រូវបានណែនាំអំពី«គោលការណ៍សីលធម៌» ដូចជា ត្រូវ«ស្រលាញ់ប្រជាជនជានិច្ច» ដើម្បី«បម្រើប្រជាជនឲ្យអស់ពីសមត្ថភាព» និងដើម្បីបម្រើ«កម្មករ និងកសិករ» ។ សមាជិកត្រូវតម្រូវឲ្យ«មានគំនិតសងសឹក» និង«មានកំហឹង»ប្រឆាំងនឹងជនក្បត់ ទោះបីជាអ្នកនោះជាអតីតកម្មាភិបាលបក្សកុម្មុយនីស្តក៏ដោយ ដូចជា សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា ហើយបានសម្លាប់ខ្លួនក្នុងឆ្នាំ១៩៧៧ ។ ឌុច បញ្ជាក់ទៀតថា បក្សកុម្មុយនីស្តកម្ពុជាចង់អប់រំប្រជាពលរដ្ឋ «បន្តិច

*ម្តងៗ» ព្រោះកាលនោះបក្សនៅក្រ ។ ឌុច បានបន្ថែមទៀតថា សូម្បីតែកម្មាំងយោធាទទួលតែរបប អង្ករតែមួយឬពីរកំប៉ុងប៉ុណ្ណោះក្នុងមួយពេល ហើយគ្មាននរណាហ៊ានតវ៉ាប្រឆាំងទៅនឹងលក្ខខណ្ឌរស់នៅ ទេ ។ ទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ច ឌុច បានផ្តល់សក្ខីកម្មថា បក្សកុម្មុយនីស្តកម្ពុជា«ព្យាយាមបង្កើត រូបិយប័ណ្ណ»តែមិនបានប្រើប្រាស់ទេ ហើយមនុស្សម្នាក់ៗត្រូវតែ«បែកគ្នាហូប» ។ ចំពោះគោលការណ៍ រៀបការនិងបង្កើតគ្រួសារ បក្សកុម្មុយនីស្តកម្ពុជាមានបទចម្រៀងមួយដែលមានន័យថា «ឪពុកម្តាយ ជាអ្នកបង្កើតអ្នក ចំណែកអង្គការគឺ ជាអ្នកមើលការខុសត្រូវ និងជាម្ចាស់អ្នក» ។*

*ទាក់ទងទៅនឹងគោលការណ៍និងការធ្វើការចម្ការ ឌុច បានបញ្ជាក់ថា សហករណ៍ត្រូវបានបង្កើត ឡើងនៅក្នុងឆ្នាំ១៩៧២ និងនៅក្នុងឆ្នាំ១៩៧៣ ហើយសហករណ៍ទ្រង់ទ្រាយធំត្រូវបានបង្កើតឡើងនៅ តំបន់រំដោះ ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ឯកសារមួយដែលចេញដោយបក្សកុម្មុយនីស្ត កម្ពុជាបានបង្គាប់ឲ្យមានការបង្កើតសហករណ៍ទូទាំងប្រទេស ។ សាសនាត្រូវបានហាមប្រាម ។ ព្រះ សង្ឃត្រូវតែកម្ទេចចោល ។ ជនជាតិខ្មែរអ៊ីស្លាមត្រូវបាន«ពង្រាយ»ឲ្យនៅគ្រប់កន្លែងទាំងអស់ទូទាំង ប្រទេសដើម្បីបំបាត់សាសនា និងដើម្បីកុំឲ្យអ្នកទាំងនោះអាចគោរពសាសនាបាន ។ ឌុច និយាយទៀត ថា «រាល់ការដាំដុះកសិផលទាំងឡាយគឺជាកម្មសិទ្ធរបស់បក្ស» ហើយប្រជាជនទទួលបានអង្ករពីកំប៉ុង រៀងរាល់ថ្ងៃ ។*

## ***មេធាវីការពារក្តីជំទាស់ទៅនឹងសក្ខីកម្មសាក្សីដែលបានអះអាងថា នេះជាការ«ស្រាវជ្រាវ» របស់គាត់***

*ម៉ៃឃើល ខាណាវ៉ាស មេធាវីអន្តរជាតិ របស់ អៀង សារី បានជំទាស់ថា ឌុច បាននិយាយ នៅក្នុងសក្ខីកម្មរបស់គាត់ដោយផ្អែកលើការ«ស្រាវជ្រាវ»របស់គាត់ ។ មេធាវីបានអះអាងថា ជាការ ចាំបាច់ដែល ឌុច ត្រូវនិយាយនូវអ្វីដែលគាត់ដឹងកាលពីជំនាន់នោះ មិនមែនអ្វីដែលគាត់ដឹងតាមរយៈ ការអាន ក្រោយរបបនោះទេ និងមិនមែនតាមការស្រាវជ្រាវរបស់គាត់ទេ ។*

*វីល្លៀម ស្មីត បានឆ្លើយតបក្នុងនាមព្រះរាជអាជ្ញាដោយអះអាងថា អ្វីដែល ឌុច សំដៅលើ «ការស្រាវជ្រាវ»របស់គាត់គឺអាចមើលបានតាមរយៈការត្រួតពិនិត្យទៅនឹងចម្លើយដែលគាត់ឆ្លើយ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ហើយថា ឌុច បានបង្រៀនពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ហើយ ដើម្បីធ្វើដូច្នេះ គាត់បានសិក្សាពីឯកសារជាច្រើនមុននឹងគាត់អាចបង្រៀនបាន ហើយគាត់បានចូលរួម ប្រជុំជាច្រើនជាមួយបក្ស ។ វីល្លៀម ស្មីត បានអះអាងថា មេធាវី ខាណាវ៉ាស អាចសួរទៅ ឌុច បន្ថែមទៀតដើម្បីឲ្យដឹងកាន់តែច្បាស់នូវអ្វីដែល ឌុច បានដឹង ហើយនេះគឺជា «ផ្នែកនៃដំណាក់កាល សួរសំណួរ»ដើម្បី «ស្វែងរកការពិត» ។*

*សេង ប៊ុនឃៀង បានស្នើ ឌុច ឲ្យពន្យល់ប្រភពនៃចំណេះដឹងរបស់គាត់ ។ ឌុច បានឆ្លើយតបថា ចំពោះគោលនយោបាយទូទៅដូចជារបបអាហារអង្ករពីរកំប៉ុងក្នុងមួយថ្ងៃត្រូវបានផ្សព្វផ្សាយជាទូទៅក្នុងប្រទេស ។ គាត់ក៏ដឹងអំពីគោលនយោបាយផ្សេងទៀតដែរ ។ ឌុច បានឲ្យដឹងថា បើសិនជាគាត់មិនដឹងពិតប្រាកដទេ គាត់មិនចែករំលែកចំណេះដឹងនេះទៅកាន់សាកលលោកទាំងមូលទេ ។ ឌុច និយាយថាគាត់ក៏បានធ្វើការស្រាវជ្រាវដែរតាមរយៈការស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ហើយគាត់ក៏ដឹងបន្ថែមទៀតទៅនឹងអ្វីដែលគាត់ធ្លាប់ដឹងកាលពីរបបនោះដែរ ។*

*មេធាវី ខណាវ៉ាស បានឆ្លើយតបវិញថា ឌុច ធ្លាប់សារភាពថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ដឹង«ហេតុការណ៍តិចតួច» តែគាត់ទើបតែដឹងច្រើនក្រោយមកទៀតទេ ។ មេធាវីបានបន្តទៀតថា ជាការចាំបាច់ណាស់ដែលអង្គជំនុំជម្រះត្រូវស្រាវជ្រាវពីប្រភពដែល ឌុច ដឹងច្រើនតាមរយៈការស្រាវជ្រាវរបស់គាត់ ។ មេធាវីបានបញ្ជាក់ថា ឌុច អាចជាអ្នកជំនាញ មិនមែនជាសាក្សីទេ ។ មេធាវី ខណាវ៉ាស បានបញ្ជាក់ថា អង្គជំនុំជម្រះគួរតែស្វែងរកពីប្រភពនៃចំណេះដឹងរបស់ ឌុច នេះ ។ ភ្លាមៗនោះ មេធាវី ផេស្តមែន របស់ នួន ជា ក៏រួមចំណែកផ្តល់សំណើបែបនេះដែរ ហើយមេធាវីរូបនេះបញ្ជាក់ថា គាត់«មិនចាប់អារម្មណ៍»នូវអ្វីដែល ឌុច បានដឹងតាមរយៈការអានក្រោយរបបខ្មែរក្រហមទ ។*

*វីល្លៀម ស្មិត បានឆ្លើយទៅក្នុងនាមព្រះរាជអាជ្ញាម្តងទៀតថា មេធាវី ខណាវ៉ាស បាន«និយាយខុស» ពេលដែលគាត់ជំទាស់ ដូចជាត្រង់គាត់និយាយថា ឌុច មិនអាចពន្យល់នូវហេតុការណ៍ដែលគាត់ដឹងកាលពីរបបកម្ពុជាប្រជាធិបតេយ្យទេ ។ វីល្លៀម ស្មិត បានបញ្ជាក់ទៀតថា ព្រះរាជអាជ្ញាមិនបានដាក់ថា ឌុច គឺជា«សាក្សីជំនាញ»ទេ ។ វីល្លៀម ស្មិត បានហៅទង្វើនេះថា «មិនត្រឹមត្រូវទេ» ដែល ឌុច មិនអាចនិយាយនូវហេតុការណ៍ផ្សេងៗក្រៅពីបរិវេណមន្ទីរស-២១នោះព្រោះគាត់ក៏ដឹងពីហេតុការណ៍ដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ លោកបានបញ្ជាក់ទៀតថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច ត្រូវបានបង្រៀនពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្ស ហើយ ឌុច ត្រូវបង្រៀនអំពីមនោគមន៍វិជ្ជានិងគោលនយោបាយផ្សេងៗទៅកាន់កម្មាភិបាលថ្នាក់ក្រោមផ្សេងទៀតដែរ ។ ដោយលើកហេតុផលដូច្នេះ វីល្លៀម ស្មិត បានអះអាងថា ចំណេះដឹងដ៏ទូលំទូលាយរបស់ ឌុច «មិនមែនតិចតួច» ដូចអ្វីដែលក្រុមការពារក្តីអះអាងទេ ។ ព្រះរាជអាជ្ញាអាចសួរសំណួរទៅកាន់ ឌុច ទៀត ហើយភាគីការពារក្តីអាចត្រួតពិនិត្យមើលចម្លើយដែល ឌុច ឆ្លើយដែរ ។*

*បន្ទាប់មក ចៅក្រមទាំងអស់របស់អង្គជំនុំជម្រះពិភាក្សាគ្នាមួយសន្ទុះ ទើបចៅក្រម ខាត់វ៉ាយថ៍ បានប្រកាសថា អង្គជំនុំជម្រះសម្រេចថា ការសួរសំណួរទៅកាន់ ឌុច ត្រូវតែសួរនូវអ្វីដែលចាំនិងដឹង*

ហើយក្រោយមក អង្គជំនុំជម្រះនឹងសម្រេចពីទម្ងន់នៃសក្ខីកម្មរបស់ ឌុច បន្ទាប់ពីភាគី ទាំងអស់ចូលរួមរួចមក។ ក្រោយមក អង្គជំនុំជម្រះបន្តាប់ឲ្យព្រះរាជអាជ្ញាបន្តនូវសំណួររបស់ខ្លួន។

មុននឹងចាប់ផ្តើមសួរសំណួរ ឌុច ស្នើសុំយោបល់រួចនិយាយថា អ្នកខ្លះអះអាងថា បក្សកុម្មុយនីស្តកម្ពុជាមាន«គោលនយោបាយបង្អត់អាហារប្រជាជន»។ គាត់ដឹងតែប៉ុណ្ណឹង ហើយចំណេះដឹងផ្សេងទៀតគាត់ដឹងតាមរយៈឯកសារ។ ចៅក្រម និល ណុន ណែនាំ ឌុច ឲ្យឆ្លើយឲ្យចំទៅនឹងសំនួរ។ បើសិនជាសំណួរនោះតម្រូវឲ្យឆ្លើយ «បាទ» ឬ «ទេ» សម្រាប់ឯកសារណាមួយ ត្រូវតែឆ្លើយតាមនោះហើយ ឌុច មិនត្រូវឆ្លើយ «តាមបែបវិភាគ» ទេ។ បន្ទាប់មក ចៅក្រមបានពន្យល់ទៅ ឌុច ម្តងទៀតអំពីប្រធានបទដែលត្រូវនិយាយនៅពេលនេះ។

## នួន ជា វាយប្រហារតម្លៃរបស់ ឌុច

អង្គជំនុំជម្រះបានប្រគល់តួនាទីនេះទៅព្រះរាជអាជ្ញាដើម្បីបន្តសួរសំណួរ ហើយសហព្រះរាជអាជ្ញា សេង ប៊ុនឃៀង បានសួរ ឌុច ពីវិធីដែលគាត់ដឹងពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មកដល់ចំណុចនេះ នួន ជា និយាយកាត់ ហើយនិយាយសំដៅទៅលើ ឌុច ថា ជា«ឈើពុក» ដែលគេមិនដែលយកឈើពុកទៅឆ្លាក់រូបព្រះទេ ដែលជាតំណាងឲ្យភាពពិត។ នួន ជា ចង់មានន័យថា គាត់បន្ទោស ឌុច ថានិយាយមិនពិត ហើយមិនមែនជាសាក្សីដ៏ត្រឹមត្រូវដែលគួរតែទុកចិត្តបាននោះទេ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ទៅនឹងអ្វីដែល នួន ជា និយាយ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ថា ជនជាប់ចោទ ឬក្រុមការពារក្តីមិនសមនឹងវាយប្រហារឬរិះគន់តម្លៃរបស់សាក្សីណាម្នាក់ទេ។ ក្រោយមក ចៅក្រម និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះគឺជាអ្នកដែលកោះហៅ ឌុច មកធ្វើជាសាក្សី មិនមែនភាគីណាកោះហៅមកទេ។ ក្រោយមក ព្រះរាជអាជ្ញាសួរទៅ ឌុច បន្តទៀត។

## ព្រះរាជអាជ្ញាបន្តសំណួរទៅ ឌុច ម្តងទៀត

សេង ប៊ុនឃៀង បានសួរទៅ ឌុច ថាតើគាត់ដឹងពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដោយរបៀបណាកាលពីរបបកម្ពុជាប្រជាធិបតេយ្យ? ឌុច បានឆ្លើយថា គាត់រៀនពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈឯកសារផ្លូវការរបស់បក្ស ដូចជាសៀវភៅទង់បដិវត្តន៍ ឯកសារសម្ងាត់ និងឯកសារផ្សេងទៀត។ សៀវភៅទង់បដិវត្តន៍គឺជាប្រភពមានសារៈសំខាន់បំផុតព្រោះអត្ថបទនៅក្នុងសៀវភៅនោះ ត្រូវបានសរសេរឡើងដោយកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយ

នីស្តកម្ពុជា ។ ឌុច និយាយថា គាត់អាន«រាល់លេខរបស់ទស្សនាវដ្តីទាំងអស់» ដើម្បីធានាថា គាត់ដឹងច្បាស់ពីគោលនយោបាយរបស់បក្ស ។ បន្ទាប់ពី ឌុច និយាយចប់ ក៏ដល់ម៉ោងសម្រាក ។

## ព្រះរាជអាជ្ញាសួរបន្ត

ក្រោយពីសម្រាក សៀង ប៊ុនយៀង ចាប់សួរទៅ ឌុច បន្តទៀតទាក់ទងទៅនឹងប្រភពចំណេះដឹងដែលគាត់បានដឹងអំបីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ ដំបូង ឌុច និយាយថា វគ្គសិក្សារៀនសូត្រដែលគាត់បានចូលរៀនម្តងៗប្រមាណជាពីរសប្តាហ៍ ។ ក្រោយមក គាត់បានបញ្ជាក់ថា កិច្ចការដែលគាត់ធ្វើគឺបញ្ហាសន្តិបាល ដូច្នេះគាត់មិនពាក់ព័ន្ធក្នុងកិច្ចការបង្កើតគោលនយោបាយអ្វីទេ ។ ទាក់ទងទៅនឹងឯកសារបក្ស«សម្ងាត់» ដែលគាត់និយាយសំអាងកាលពីមុននេះ ឌុច បានបញ្ជាក់ថា សូម្បីតែសៀវភៅទង់បដិវត្តន៍ក៏ចាត់ទុកថាជាឯកសារ«សម្ងាត់»ដែរ ព្រោះឯកសារនេះចែកជូនចំពោះ តែសមាជិកបក្សប៉ុណ្ណោះ ។ ឌុច បានបន្ថែមទៀតថា ឯកសារផ្សេងទៀតត្រូវបានចាត់ទុកថាសម្ងាត់ហើយឯកសារនោះចែកជូនទៅបុគ្គលមួយចំនួនប៉ុណ្ណោះ ។ ក្រោយមក ឌុច រៀបរាប់អំពីទិដ្ឋភាពទាំងមូលនៃវគ្គអប់រំដែលគាត់បានធ្វើនៅមន្ទីរស-២១ ដែលពេលនោះគាត់បានអប់រំដល់អ្នកចូលរួមទាំងអស់អំពីគោលនយោបាយបក្សនិងវិធីសាស្រ្តសួរចម្លើយ ។ នៅពេលសួរអំពីគោលបំណង និងមនោគមន៍វិជ្ជា «ជាចម្បង» របស់បក្សកុម្មុយនីស្តកម្ពុជា ឌុច បានឆ្លើយតបថា មុនឆ្នាំ១៩៧០ បក្សមានគំនិតថា «ប្រជាជនត្រូវតែរំដោះ» ដោយការវាយប្រយុទ្ធប្រឆាំងនឹង«ប្រតិកិរិយានិងមូលធននិយម» ។ ក្រោយឆ្នាំ១៩៧៥ មាគ៌ាបក្សចំនួនពីរត្រូវបានបញ្ចូលគឺ កិច្ចការការពារប្រទេស និង«កសាង»ប្រទេស ។ ចំណែកឯការប្រើប្រាស់អំពើហិង្សាដើម្បីទទួលបាននូវគោលបំណងទាំងនោះ ឌុច បានឆ្លើយថា គាត់ជឿថា ការប្រើប្រាស់កមាំងដើម្បីសម្រេចបានគោលបំណងគឺ ជាការអនុវត្តតាមបទដ្ឋានត្រឹមត្រូវដែលប្រទេសនៅលើពិភពលោកនេះប្រើប្រាស់ ហើយបក្សកុម្មុយនីស្តកម្ពុជាក៏ប្រើប្រាស់បទដ្ឋាននេះដែរ ។

សេង ប៊ុនយៀង បានសួរទៅ ឌុច អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ។ ឌុច បានឆ្លើយថា គាត់ត្រូវបាន «អប់រំ» នៅពេលនោះថា «ប្រជាជនត្រូវតែជម្លៀសនៅពេលដែលខ្មាំងវាយប្រហារយើង» ។ គោលបំណងនៃគោលនយោបាយនេះគឺដើម្បីផ្តាច់ការគាំទ្រខបត្តម្ភដល់ខ្មាំងដោយជម្លៀសប្រជាជនចេញ ។ គាត់មិនដឹងដឹងថានឹងមានរឿងអ្វីកើតឡើងទេ បើសិនជាប្រជាជនមិនចង់ជម្លៀសចេញនោះ ។ ឌុច និយាយថា ក្នុងខែមេសា ឆ្នាំ១៩៧១ គាត់មើលពីការជម្លៀសប្រជាជនចេញពីទីក្រុង តែគាត់មិនដឹងប្រាកដទេថាការជម្លៀសនោះធ្វើឡើងដោយស្ម័គ្រចិត្តឬយ៉ាងណានោះ ។ ក្រោយមក ឌុច ដឹងថា ការជម្លៀសនេះត្រូវបានធ្វើ ចប់សព្វគ្រប់ហើយនៅពេលដែលគាត់មកដល់ភ្នំពេញ ហើយពេលនោះទីក្រុងមានភាពទទេស្អាត ។ ទាក់

ទងទៅនឹងការជម្លៀស ឌុច បញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបានបង្ខំប្រជាជនឲ្យចេញពីផ្ទះសម្បែង ហើយពេលនោះ គាត់ត្រូវបានជូនដំណឹងមកថា ប្រជាជនត្រូវបានជូនដំណឹងថា ការជម្លៀសគឺ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក ។ ឌុច និយាយថា អ្នកដែលបដិសេធមិនព្រមចេញនិងត្រូវបាញ់សម្លាប់ ។ ក្រោយមក ឌុច និយាយថា មិនមាននរណាហ៊ានប្រាប់គាត់ទេនៅពេលសួរអំពីជោគវាសនារបស់ប្រជាជនដែលមិនព្រមជម្លៀសចេញនោះ ។ បើតាមគាត់គិត គាត់មិនដែល«ពិចារណា» ថាហេតុអ្វីបានជាមានការបញ្ជាឲ្យជម្លៀសទេ ទោះបីជាក្រោយឆ្នាំ១៩៧៩ក៏ដោយ ។ ឌុច បដិសេធថា គាត់មិនដឹងពី «មូលហេតុពិត»ថាហេតុអ្វីបានជាទីក្រុងត្រូវបានជម្លៀសទេ ។ ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាបញ្ជាក់ត្រឹមតែការជម្លៀសគឺជាផ្នែកមួយដើម្បីទទួលបានជ័យជម្នះ និងដើម្បីឆ្ពោះទៅរករបបសង្គមនិយម ។

ទាក់ទងទៅនឹងការជម្លៀសនៅក្នុងប្រទេសកម្ពុជា ឌុច បានបញ្ជាក់ថា គាត់ទើបតែឃើញឯកសារមួយនៅក្នុងករណី០ ០ ១ដែលឯកសារនោះត្រូវបានផ្ញើដោយ សោ ភឹម ជូនចំពោះ ប៉ុល ពត ដោយនិយាយអំពីការជម្លៀសប្រជាជនតាមដងទន្លេមេគង្គ ។ ឌុច បញ្ជាក់ថា នៅពេលនោះ គាត់ចង់រកព័ត៌មានអតីតគ្រូរបស់គាត់ម្នាក់ ដែលគាត់«ពេញចិត្ត» ហើយដែលគាត់ដឹងថាគ្រូម្នាក់នោះត្រូវបានជម្លៀសចេញនិងសម្លាប់ ។

## មេធាវីការពារក្តីរបស់ អៀង សារី ជំទាស់ម្តងទៀត

មកដល់ចំណុចនេះ មេធាវីការពារក្តីរបស់ អៀង សារី គឺ ម៉ៃឃើល ខាណាវ៉ាស ជំទាស់ម្តងទៀត ហើយបញ្ជាក់ថា ព្រះរាជអាជ្ញាកំពុងតែសួរសំណួរមិនសមស្រប ដោយនាំ ឌុច ទៅនិយាយអំពីអ្វីដែលផ្តល់ចំណេះដឹងដល់គាត់វិញ ។ មេធាវី ខាណាវ៉ាស បានបញ្ជាក់ថា នេះគឺមិនមែនជាវិធីសាស្រ្តសមស្របដែលត្រូវយកមកប្រើទេពីព្រោះ ឌុច បានបញ្ជាក់រួចហើយថា គាត់មិនដឹងច្រើនទេទាក់ទងទៅនឹងការជម្លៀសក្នុងរបកម្ពុជាប្រជាធិបតេយ្យ ។

សេង ប៊ុនឃៀង បានឆ្លើយតបដោយសម្រួលសំណួរឡើងវិញ ហើយសួរ ឌុច ថាតើគាត់អាចរៀបរាប់ពីការជម្លៀសប្រជាជនទៅ «គ្រប់កន្លែង» បានទេ ។ ឌុច ឆ្លើយថា គាត់សង្កេតឃើញថាប្រជាជនទាំងអស់ត្រូវបានជម្លៀសនិងធ្វើបន្សុទ្ធកម្មក្នុងឆ្នាំ១៩៧៥ ។ ឌុច បានបញ្ជាក់ទៀតថា អ្នកដែលត្រូវបន្សុទ្ធកម្មត្រូវបានសម្លាប់ ចំណែកអ្នកដែលត្រូវបានជម្លៀសត្រូវបានបញ្ជូនទៅក្រោមការគ្រប់គ្រងរបស់«ប្រជាជនចាស់» ។ ប្រជាជនដែលត្រូវបានជម្លៀសត្រូវបានហៅថាជា «ប្រជាជន១៧ មេសា» ។ ឌុច បញ្ជាក់ទៀតថា នៅពេលដែលគាត់សួរអំពីការជម្លៀស កម្មាភិបាលបក្សម្នាក់បានប្រាប់គាត់ថា អ្នកដែលដាក់តាមរថយន្តនឹងត្រូវកម្ទេច ចំណែកឯអ្នកដែលដើរត្រូវទុក ។

នៅពេលសួរអំពីលក្ខខណ្ឌការងារនៅសហករណ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបង្កើត«កម្មវិធីបន្ទាន់»មួយនៅព្រះវិហារ ដើម្បីបង្រៀនពីរបៀបធ្វើកសិកម្ម ហើយក្រោយមកអ្នកចូលរួមទាំងអស់ត្រូវបានបញ្ជូនទៅតំបន់រំដោះដើម្បីធ្វើកសិកម្ម ។ មនុស្សទាំងអស់ត្រូវធ្វើការ រួមទាំងធ្វើស្រែផង ឌុច បញ្ជាក់ទៀតថា នៅក្នុងសហករណ៍នីមួយៗ មាន«លេខាបក្ស»ម្នាក់ដែលដឹកនាំប្រជាជនធ្វើការ ។ សមាជិកបក្សនោះត្រួតពិនិត្យមើលកិច្ចការទាំងអស់ ហើយរបបម្ហូបអាហារទូទៅគឺអង្ករពីរកំប៉ុងក្នុងមួយថ្ងៃ ។ ឌុច បានបញ្ជាក់ទៀតថា នៅសហករណ៍ព្រៃសរដែលគាត់ដឹកនាំធ្វើការ ប្រជាជនទាំងនោះគឺជាកសិករដែលត្រូវតែធ្វើស្រែ ហើយត្រូវបានចាត់ទុកដូច«ប្រជាជនជម្លៀស»ផ្សេងទៀតដែរ ព្រោះនេះជាជំហររបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការចាត់ថ្នាក់មនុស្ស ។

បន្ទាប់មក ឌុច បានផ្ដល់សក្ខីកម្មថា កសិករត្រូវបានតម្លើងឲ្យកាន់តំណែងជាកម្មាភិបាលនៅក្នុងជួរបក្សនិងយោធាដើម្បីអនុវត្តគោលការណ៍បក្សកុម្មុយនីស្តកម្ពុជាដែលដឹកនាំដោយកសិករ ។ គោលនយោបាយនៃការលើកតម្កើងកសិករក្រីក្រនេះ «មិនមានអ្វីគួរឲ្យអាថ៌កំបាំង»ទេ ហើយត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យដែរ ដែលបានចែងថា ប្រទេសកម្ពុជា «គឺជារបស់កម្មករកសិករ» ។ ប្រជាជន«ថ្មី» និងប្រជាជន«ចាស់»ត្រូវធ្វើការទាំងអស់ តែដើម្បីក្លាយជាសមាជិកបក្សបុគ្គលនោះត្រូវតែជាវណ្ណៈកសិករនៃសម័ន្ទយុវជនកម្ពុជា ។ ក្រោយមក ឌុច និយាយទៀតថា សហករណ៍ព្រៃសរត្រូវបានបង្កើតឡើងដោយ សុន សេន ដើម្បីធ្វើជាកន្លែងអប់រំវណ្ណៈសក្តិភូមិ ដើម្បី«កសាងខ្លួនឯង» ។ គោលបំណងនៃការបង្កើតព្រៃសរ គឺដើម្បី«កែខ្លួន» ដើម្បីឲ្យអ្នកទាំងនោះចូលធ្វើយោធាបាន តែតំបន់នោះមិនទទួលបាន«ជោគជ័យ»ទេក្នុងការធ្វើដូច្នេះ ។ ពេលនិយាយដល់ចំណុចនេះ ចៅក្រម និល ណុន និយាយកាត់ដោយប្រកាសសម្រាកនៅពេលរសៀល ។

ក្រោយពីសម្រាក អង្គជំនុំជម្រះបានប្រគល់ឱកាសនេះទៅ នួន ជា ដែលស្នើសុំចេញពីបន្ទប់សវនាការដោយហេតុផលថាហត់នឿយនិងចង់សម្រាក ។ អង្គជំនុំជម្រះយល់ព្រមទៅនឹងសំណើនេះ ហើយណែនាំឲ្យក្រុមការពារក្ដីរបស់ នួន ជា ប្រគល់លិខិតជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះដោយមានហត្ថលេខាឬស្នាមម្រាមដៃរបស់ជនជាប់ចោទ នួន ជា ។ នួន ជា ត្រូវបាននាំទៅកាន់បន្ទប់រង់ចាំ ។

ពេលនេះ មេធាវី ដេស្តមែន បានជូនដំណឹងទៅអង្គជំនុំជម្រះថា នួន ជា មិនចង់លះបង់សិទ្ធក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការទេ តែគាត់មិនអាចបន្តអង្គុយតទៅទៀតបាន ។ ដូច្នេះមេធាវី ដេស្តមែន បានបញ្ជាក់ថា នួន ជា ចង់ស្នើទៅអង្គជំនុំជម្រះបញ្ចប់សម្រាប់ថ្ងៃនេះដោយរំពឹងថា នៅថ្ងៃស្អែកគាត់អាចតាមដានដោយមិនអាក់ខានចំណុចណាមួយ ។

ក្រោយមក ចៅក្រមបានជំនុំគ្នាមួយសន្ទុះ លោកចៅក្រមបានកត់សម្គាល់អំពីសំណើរបស់មេធាវី នួន ជា និងបញ្ជាក់ថា សំណើរបស់មេធាវី ដេស្តមែន «មិនមានការពាក់ព័ន្ធ» ទៅនិងសំណើ

សុំលះបង់សិទ្ធិរបស់ នួន ជា ទេ។ ដូច្នេះ អង្គជំនុំជម្រះក៏បង្គាប់ឲ្យវេជ្ជបណ្ឌិតប្រចាំការចូលទៅត្រួតពិនិត្យ នួន ជា ជាបន្ទាប់ដើម្បីវាយតម្លៃពីស្ថានភាពរបស់ជនជាប់ចោទ ថាតើគាត់អាចបន្តទៀតបានឬអត់?

## អង្គជំនុំជម្រះបញ្ចប់ដំណើរការដោយសារតែ«មានការជ្រៀតជ្រែក»ពីសំណាក់មេធាវីការពារក្ដីជាមួយវេជ្ជបណ្ឌិត

វេជ្ជបណ្ឌិតរបស់អង្គជំនុំជម្រះ បានចាកចេញពីបន្ទប់សវនាការដើម្បីទៅត្រួតពិនិត្យស្ថានភាពជម្ងឺរបស់ នួន ជា ហើយភ្លាមនោះមេធាវី ផេស្តូមែន ក៏ចេញទៅតាមដែរដើម្បីមើលកូនក្តីរបស់ខ្លួននៅបន្ទប់រង់ចាំ។ នៅពេលនេះ ចៅក្រម ខាតរ៉ាយច៍ និង ចៅក្រម និល ណុន ក៏និយាយគ្នាដែរ។ ក្រោយមក ចៅក្រម និល ណុន បានបង្គាប់ឲ្យក្រឡាបញ្ជីទៅតាមដានមេធាវី ផេស្តូមែន ហើយប្រាប់មេធាវីថាមិនត្រូវទៅក្បែរវេជ្ជបណ្ឌិតទេដើម្បីឲ្យវេជ្ជបណ្ឌិតពិនិត្យសុខភាពបានដោយឯករាជ្យ។ ពេលនោះចៅក្រម និល ណុន បានប្រកាសថា ប្រសិនបើលោកមេធាវី ផេស្តូមែន ទៅកន្លែងវេជ្ជបណ្ឌិតពិនិត្យជនជាប់ចោទ នោះគឺជាការជ្រៀតជ្រែកដល់ឯករាជ្យភាពរបស់គ្រូពេទ្យ។ លោកចៅក្រមបានថ្លែងថា បើសិនជាគាត់ដឹងថា មេធាវី ផេស្តូមែន ចូលទៅក្នុងជាមួយវេជ្ជបណ្ឌិតមែននោះ និង«មានបញ្ហា»។ ក្រោយមក ចៅក្រម និល ណុន បានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ថា ការផ្អើសក្ដីកម្ម ឌុច និងបន្តនៅព្រឹកស្អែកទៀត ហើយនៅថ្ងៃព្រហស្បត្តិ៍និងមិនមានសវនាការទេ។ ពេលនេះ មេធាវី ផេស្តូមែន ក្រោកឈរនិងចង់និយាយតែម៉ៃក្រូហ្វូនរបស់គាត់មិនបើកទេ។ អង្គជំនុំជម្រះមិនអើពើទៅនិងអ្វីដែល មេធាវី ផេស្តូមែន និយាយទេ ហើយប្រកាសបញ្ចប់។

**-ចប់-**